រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃ ព្រហស្បតិ៍ ទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

## ***គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាៈ ការអនុវត្ត និងការតម្លើងប្រាក់ឈ្នួល ជួយដល់កម្មករនិយោជិតកាត់ដេរ***

ភ្នំពេញ ប្រទេសកម្ពុជា- *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) ស្វាគមន៍ចំពោះសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារដល់កម្មករនិយោជិតកាត់ដេរ និងស្បែកជើង។

លោកស្រី ជីល ថាក់ឃើ ប្រធានទីប្រឹក្សាបច្ចេកទេសនៃ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានមានប្រសាសន៍ថា «រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់រោងចក្រគួរត្រូវបានកោតសរសើរចំពោះវិធានការណ៍ដ៏ល្អនេះ ដែលនឹងជួយផ្គត់ផ្គង់ដល់ជីវភាពរស់នៅដល់កម្មករនិយោជិតប្រមាណ ៤០០ ០០០ នាក់ ហើយនេះក៏បានជួយដល់ប្រជាជនកម្ពុជារហូតដល់ ១,៧ លាននាក់ផ្សេងទៀតផងដែរ។»

លោកស្រីបន្តទៀតថា «ការតម្លើងនូវប្រាក់ឈ្នួលនេះគឺជាការបង្កើតឱ្យមានការលើកទឹកចិត្តនៅក្នុងបរិយាកាសផ្លាស់ប្តូរមួយយ៉ាងលឿនហើយការណ៍នេះនឹងមិនអាចកើតមានឡើងប្រសិនបើគ្មានការចូលរួមនិងការប្តេជ្ញាចិត្តរបស់សហជីពដែលបានធ្វើការប្រឹងប្រែងក្នុងនាមកម្មករនិយោជិតទាំងឡាយ។»

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសកាលពីម្សិលមិញថា កម្មករនិយោជិតកាត់ដេរ និងស្បែកជើងនៅកម្ពុជា នឹងទទួលបានប្រាក់ឧបត្ថម្ភថែទាំសុខភាពរៀងរាល់ខែចំនួន ៥ ដុល្លារចាប់ពីខែ មករា ឆ្នាំ២០១២ តទៅ។ វិធានការណ៍នេះកើតមានឡើងយ៉ាងឆាប់រហ័សបន្ទាប់ពីមានការចេញនូវប្រកាសថ្មីមួយស្តីពី *ការគ្រប់គ្រងកិច្ចសន្យាជួលផលិតបន្តក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងវាយនភ័ណ្ឌ* ដែលជាលើកដំបូងក្នុងការតម្រូវឱ្យរោងចក្រកាត់ដេរជួលផលិតបន្តចុះបញ្ជីជាមួយកម្មវិធីត្រួតពិនិត្យលក្ខខណ្ឌការងាររបស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*។

ប្រការទី៣ នៃប្រកាស នោះបានចែងថា «មានតែរោងចក្រដែលជាសមាជិករបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)ដែលបានចុះបញ្ជីជាមួយ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* តាមគំរូសេចក្តីប្រកាសដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម ទើបមានសិទ្ធិចុះកិច្ចសន្យាផលិតបន្តបាន។»

លោកស្រី ជីល ថាក់ឃើ បានមានប្រសាសន៍បន្ថែមទៀតថា «នៅមានបញ្ហាប្រឈមជាច្រើនទៀតនៅក្នុងឧស្សាហកម្មនេះ តែទោះជាយ៉ាងក៏ដោយ ការផ្តល់បន្ថែមនូវប្រាក់ឈ្នួលនេះគឺជាជំហានមួយទៀតនៅក្នុងទិសដៅ

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

ដ៏ត្រឹមត្រូវ។ ជាពិសេសនោះ ការតម្លើងនេះកើតឡើងក្រោយពីមានកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហារោងចក្រជួលផលិតបន្ត។ វាមានសារៈសំខាន់ដែលយើងក្នុងនាមជាតួអង្គក្នុងវិស័យកាត់ដេរធ្វើការរួមគ្នាដើម្បីសម្រេចឱ្យបាននូវបទដ្ឋានការងារប្រកបដោយគុណភាពខ្ពស់ដល់កម្មករនិយោជិតនៅតាមរោងចក្រទាំងឡាយក្នុងប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ

កញ្ញា Maeve Galvin
មន្ត្រីទំនាក់ទំនងព័ត៌មាន និងតស៊ូមតិ
អង្គការពលកម្មអន្តរជាតិ ILO
អ៊ីម៉េលៈ galvin@ilo.org
ទូរស័ព្ទៈ ០៧៨ ៩៨៥ ៥៦៣